# ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
# ព្រឹត្តិបត្រព័ត៌មាន

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៧ លេខ ០៣៧
ខែ វិច្ឆិកា_ធ្នូ ២០១០
បោះពុម្ពផ្សាយដោយ
អគ្គលេខាធិការដ្ឋាននៃ ក.ក.រ


បម្រើប្រជាជនឲ្យបានកាន់តែល្អប្រសើរឡើង ដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងវិបុលភាពប្រទេសជាតិយើង



## សម្រង់ប្រសាសន៍ សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងការងារ កំណែទម្រង់រដ្ឋបាល

" អ្វីដែលជាសំណូមពរធំបំផុតរបស់ខ្ញុំនៅពេលនេះ គឺសូមឲ្យឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ជាមន្ត្រីរាជការ ធ្វើកិច្ចការដែលគប្បីចាំបាច់ត្រូវធ្វើ ដោយខានមិនបានក្នុងកាតព្វកិច្ចជាអ្នកបម្រើប្រជាពលរដ្ឋ...

(តទៅទំព័រទី១៧)

## វគ្គបណ្តុះបណ្តាល ស្តីពី ការកែលម្អការផ្តល់សេវាសាធារណៈ ដែលអនុវត្តនៅក្នុងរដ្ឋបាលសាធារណៈ

ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ គឺជាយុទ្ធសាស្ត្រអាទិភាពមួយដ៏សំខាន់នៅក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

(តទៅទំព័រ ២)

## សិក្ខាសាលា ស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅកម្ពុជា លើប្រធានបទ "ការគ្រប់គ្រងវដ្តនៃគម្រោង" និង "វិធីសាស្ត្ររៀបចំករណីសិក្សា"

កាលពីថ្ងៃទី ២៧ ដល់ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០១០ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដោយមានការសហការឧបត្ថម្ភគាំទ្រពីមូលនិធិសន្តិភាពសាសាកាវ៉ា (ជប៉ុន) បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលមួយក្រោមគម្រោងស្តីពី ការអភិវឌ្ឍ

(តទៅទំព័រ ៣)

# វគ្គបណ្តុះបណ្តាល ស្តីពី ការកែលម្អការផ្តល់សេវាសាធារណៈ.....



ឯកឧត្តម **ង៉ោ ហុងលី** អគ្គលេខាធិការ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី ការកែលម្អការផ្តល់សេវាសាធារណៈ





សកម្មភាពវគ្គបណ្តុះបណ្តាលស្តីពី ការកែលម្អការផ្តល់សេវាសាធារណៈ

ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព គឺជាឧបករណ៍ដ៏សំខាន់មិនអាចធ្វេសប្រហែស ឬមើលរំលងបានដែលត្រូវតែផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តគ្រប់វិស័យនៅទូទាំងប្រទេស ស្របទៅតាមទីកន្លែង ពេលវេលា និងតម្រូវការរបស់ប្រជាពលរដ្ឋ ដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា និងការកាត់បន្ថយភាពក្រីក្រ។

ក្នុងទស្សនទានខាងលើនេះ កាលពីថ្ងៃទី ២៧-២៨ ខែ កញ្ញា ឆ្នាំ ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការកែលម្អការផ្តល់សេវាសាធារណៈ ដែលអនុវត្តនៅក្នុងរដ្ឋបាលសាធារណៈ ដែលមានសិក្ខាកាមចូលរួមមកពី ១០ ក្រសួង ស្ថាប័ន គឺ ក្រសួងទេសចរណ៍, ក្រសួងមហាផ្ទៃ, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងសុខាភិបាល, សាលារាជធានីភ្នំពេញ, អង្គភាពប្រឆាំងអំពើពុករលួយ និងអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសរុបមានចំនួន ៣០នាក់ ។

វគ្គបណ្តុះបណ្តាលនេះមានការចូលរួមធ្វើបទបង្ហាញពីសាស្ត្រាចារ្យល្បីៗមកពីប្រទេសបារាំងរួមមានលោក Jean-Jaques PAUL សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Lyon លោក Bertrand TORTELILIE សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យ Lille 1 និងលោក Thierry SCHWARZ ប្រធានគម្រោងកិច្ចសហប្រតិបត្តិការវិស័យរដ្ឋបាលសាធារណៈ និងជាទីប្រឹក្សាអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។

គោលបំណងនៃការរៀបចំវគ្គបណ្តុះបណ្តាលនេះឡើង គឺដើម្បីប្រមូលផ្តុំគំនិត ទស្សនៈ អនុសាសន៍ និងស្មារតីរួមតាមរយៈការពិនិត្យ ដកបទពិសោធន៍ លើការអនុវត្តជាក់ស្តែងនៃការផ្តល់សេវាសាធារណៈ ហើយរិះរកវិធីសាស្ត្រល្អៗ និងលទ្ធភាពប្រកបដោយប្រសិទ្ធភាព ក្នុងការកែលម្អនីតិវិធី និងដំណើរការនៃការផ្តល់សេវាសាធារណៈ។ លទ្ធផលដែលទទួល បានពីការអនុវត្តជាក់ស្តែងនៅក្នុងវគ្គបណ្តុះបណ្តាលនេះ នឹងក្លាយជាមូលដ្ឋាននៃការបង្កើតទម្រង់គំរូ សម្រាប់ការកែលម្អនីតិវិធី និងដំណើរការផ្តល់សេវាសាធារណៈ។

ឯកឧត្តម **ង៉ោ ហុងលី** អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដែលបានចូលរួមជាអធិបតីភាព

( តទៅទំព័រ ៥)

# សិក្ខាសាលា ស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅ......

សមត្ថភាពមន្ត្រីរាជការនៅប្រទេសកម្ពុជា ដែលមានរយៈពេលបួនថ្ងៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ង៉ោ ហុងលី** អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។ សិក្ខាសាលាបានផ្តោតលើមុខវិជ្ជាសំខាន់ៗចំនួនពីរបន្តបន្ទាប់គ្នាគឺ "ការគ្រប់គ្រងវដ្តនៃគម្រោង" (ថ្ងៃទី២៧-២៨ ខែកក្កដា) និង "វិធីសាស្ត្ររៀបចំករណីសិក្សា" (ថ្ងៃទី២៩-៣០ ខែកក្កដា)។ សិក្ខាកាមដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះមានប្រមាណជា ៦០ រូប (មួយមុខវិជ្ជា ៣០ រូប) ដែលជាមន្ត្រីជំនាញ និងគ្រូបង្គោលនៅតាមគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល រួមទាំងសាលាភូមិន្ទរដ្ឋបាល រាជបណ្ឌិត្យសភាកម្ពុជា និងវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។

កន្លងមក (កាលពីចុងខែវិច្ឆិកា និងដើមខែធ្នូ ឆ្នាំ ២០០៩) អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល បានរៀបចំសិក្ខាសាលាសាកល្បងចំនួន ០២ លើករួចមកហើយ ជាមួយមូលនិធិសន្តិភាពសាសាការ៉ា ស្តីពី "ការគ្រប់គ្រងវដ្តនៃគម្រោង" និង"វិធីសាស្ត្ររៀបចំករណីសិក្សា" ក្នុងគោលបំណងប្រមូលផ្តុំមូលដ្ឋាននៃចំណេះដឹង និងបទពិសោធន៍ សម្រាប់រៀបចំគម្រោងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការនៅកម្ពុជា។ ក្រោយពីបានឆ្លងកាត់សិក្ខាសាលាសាកល្បងរួចមក មូលនិធិសន្តិភាពសាសាការ៉ា និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលបានរៀបចំជាគម្រោងរយៈពេល ០៣ឆ្នាំ សម្រាប់អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅប្រទេសកម្ពុជា ហើយដែលក្នុងឆ្នាំទី ១ នេះ សិក្ខាសាលានឹងរៀបចំឡើងចំនួន ០៣ វគ្គ។

គោលបំណងនៃការរៀបចំសិក្ខាសាលានេះ ក៏ដូចជាគោលបំណងនៃគម្រោងរយៈពេល ០៣ ឆ្នាំ ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅកម្ពុជា គឺដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រីរាជការស៊ីវិលរបស់កម្ពុជា នៅតាមក្រសួងស្ថាប័ន ក្នុងការកែលម្អគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងពង្រឹងមនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការឲ្យបានសក្តិសមជាអ្នកបម្រើផលប្រយោជន៍ប្រជាជន ដែលជាការរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍប្រទេសជាតិ និងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ក៏ដូចជាឆ្លើយតបទៅនឹងគោលបំណងរួមរបស់កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលគឺ **"បម្រើប្រជាជនឲ្យបានកាន់តែល្អប្រសើរឡើង"**។




ឯកឧត្តម **ង៉ោ ហុងលី** អគ្គលេខាធិការ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (ឆ្វេង) និងលោកបណ្ឌិត **Akinori SEKI** (ស្តាំ) ប្រធានមូលនិធិសន្តិភាពសាសាការ៉ា ជាអធិបតីក្នុងពិធីបិទអង្គសិក្ខាសាលា



សកម្មភាពសិក្ខាសាលាក្រោមគម្រោងស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ

(តទៅទំព័រ ៦)

# ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយប្រតិបត្តិការអាទិភាព

ឯកសារណែនាំនេះរៀបរៀងឡើងដើម្បីជាជំនួយដល់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ក្នុងការបង្កើត គ្រប់គ្រង និងតាមដានត្រួតពិនិត្យលើគម្រោងចំណាយប្រតិបត្តិការអាទិភាព ដើម្បីគាំទ្រដល់កម្មវិធី ឬគម្រោងនានានៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ។ ឯកសារណែនាំនេះនឹងធ្វើការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពនៅពេលដែលមានសំណូមពរពីបណ្តាក្រសួង ស្ថាប័នដែលជាអ្នកអនុវត្ត។

## ក. តើចំណាយប្រតិបត្តិការអាទិភាពជាអ្វី ?

### ១. និយមន័យ

ចំណាយប្រតិបត្តិការអាទិភាព គឺជាចំណាយប្រតិបត្តិការសរុបសម្រាប់ផ្តល់ជូនមន្ត្រីរាជការដែលត្រូវបានជ្រើសរើសឲ្យបំពេញការងារក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ។ ចំណាយប្រតិបត្តិការអាទិភាពនឹងត្រូវបញ្ចប់នៅពេលលទ្ធផលដែលបានគ្រោងទុកត្រូវបានសម្រេច ឬគម្រោង ឬកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍត្រូវបានបញ្ចប់។ ចំណាយប្រតិបត្តិការអាទិភាព មិនមែនជាប្រាក់បៀវត្ស ឬជាប្រាក់ឧបត្ថម្ភបន្ថែមលើបៀវត្សឡើយ។

### ២. វត្ថុបំណង

ចំណាយប្រតិបត្តិការអាទិភាព ត្រូវបានបង្កើតឡើងក្នុងវត្ថុបំណង ៖

១-ធានានិរន្តរភាពនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអាទិភាពនានានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងក្របខ័ណ្ឌនៃភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់កម្ពុជា

២-ឆ្លើយតបទៅនឹងលក្ខខណ្ឌនៃការអនុវត្តរបស់រាជរដ្ឋាភិបាល

៣-សម្រួលដល់ការធ្វើសុខដុមនីយកម្ម និងការកាត់តម្រឹមការអនុវត្តរបស់ដៃគូអភិវឌ្ឍនានា

៤-សម្រួលដល់ការអនុវត្តកំណែទម្រង់នានា ដែលពាក់ព័ន្ធនឹងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល ដូចជាកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស កំណែទម្រង់ការអភិវឌ្ឍធនធានមនុស្ស និងកំណែទម្រង់ប្រព័ន្ធលាភការ។

### ៣. គោលការណ៍រួម

១-ចំណាយប្រតិបត្តិការអាទិភាពផ្អែកលើគោលការណ៍ដូចខាងក្រោម ៖

- **សមធម៌** ៖ ការអនុវត្តត្រូវឲ្យមានភាពយុត្តិធម៌ទាំងនៅក្នុងអង្គភាពរដ្ឋបាល និងក្នុងចំណោមអង្គភាពរដ្ឋបាល
- **ឯកភាព** ៖ ការអនុវត្តត្រូវចៀសវាងការបង្កើតឲ្យមានការបែកបាក់នៅក្នុងអង្គភាពរដ្ឋបាល
- **ចីរភាព** ៖ សមត្ថភាពរបស់ស្ថាប័នត្រូវបានលើកកម្ពស់ និងមានចីរភាពទៅអនាគត
- **លក្ខណសម្បត្តិសក្តិសម** ៖ ការជ្រើសរើសមន្ត្រីដែលត្រូវតែងតាំងក្នុងគម្រោងត្រូវ ផ្អែកលើគុណវុឌ្ឍិធ្វើការងារនោះ
- **ជនុះម្ចាស់ការ** ៖ ប្រព័ន្ធនេះនឹងផ្តល់មធ្យោបាយដល់មន្ត្រីដែលត្រូវតែងតាំងក្នុងគម្រោង ឲ្យបំពេញការងារប្រកបដោយភាពស័ក្តិសិទ្ធ ក្នុងស្មារតីនៃភាពជាម្ចាស់ និងម្ចាស់ការងារ
- **តម្លាភាព** ៖ ព័ត៌មានសម្រាប់ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យ ត្រូវមានលក្ខណៈងាយស្រួលក្នុងការទទួលយក
- **ប្រសិទ្ធភាពការងារ** ៖ ការគ្រប់គ្រងត្រូវធ្វើឡើងដោយផ្អែកលើលទ្ធផលជាមូលដ្ឋាន ហើយការផ្តល់ការចំណាយត្រូវស្របតាមលទ្ធផលដែលសម្រេចបាន។

២-អ្នកទទួលបានចំណាយប្រតិបត្តិការអាទិភាព គឺជា

(តទៅទំព័រ ៧)

## វគ្គបណ្តុះបណ្តាល ស្តីពី ការកែលម្អការផ្តល់សេវាសាធារណៈ.....

ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនាពេលនោះ បានថ្លែងសង្កត់ធ្ងន់ថាការលើកកម្ពស់ការផ្តល់សេវាសាធារណៈ គឺជាគោលដៅអាទិភាពដ៏សំខាន់នៅក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ។ ដើម្បីសម្រេចគោលដៅនេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលដែលស្ថិតក្រោមការដឹកនាំផ្ទាល់ពីឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល បានរៀបចំនូវកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ក្នុងគោលបំណងបម្រើប្រជាជនឲ្យបានកាន់តែល្អប្រសើរឡើង ដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងវិបុលភាពរបស់ប្រទេសជាតិយើង ។ ដើម្បីសម្រេចគោលបំណងនេះ យើងត្រូវប្រែក្លាយរដ្ឋបាលសាធារណៈឲ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងមានការជឿទុកចិត្តពីប្រជាជន។

រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈនាថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០០៦ សម្រាប់ជាគោលការណ៍រួមក្នុងការអនុវត្តការកែលម្អការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ដើម្បីជំរុញការអនុវត្តគោលនយោបាយខាងលើឲ្យមានប្រសិទ្ធភាព ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលបានសហការយ៉ាងជិតស្និទ្ធជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំចងក្រង និងបោះពុម្ព "កម្រងព័ត៌មានសេវាសាធារណៈ "ចង្កោមសេវាទី១ និងចង្កោមសេវាទី៤ ព្រមទាំងបានធ្វើការផ្សព្វផ្សាយតាមរយៈសិក្ខាសាលាថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ កិច្ចប្រជុំអន្តរក្រសួង និងនៅក្នុងសន្និសីទអន្តរជាតិកាលពីខែមិថុនាកន្លងមកថ្មីៗនេះ។ កម្រងព័ត៌មានសេវាសាធារណៈនេះ គឺជាកម្រងឯកសារដ៏សំខាន់ ដែលប្រមូលផ្តុំនូវព័ត៌មានចាំបាច់នានាពាក់ព័ន្ធនឹងសេវាសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា ហើយឯកសារនេះ គឺជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ក្នុងការពង្រឹងតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ជាពិសេសគឺជាឯកសារសម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ក្នុងការផ្តល់សេវាសាធារណៈផងដែរ។

ឯកឧត្តម **ង៉ោ ហុងលី** បានបន្ថែមទៀតថា ដោយមានការចង្អុលបង្ហាញទិសពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងការណែនាំផ្ទាល់ពីឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល យើងសម្រេចបានសមិទ្ធផលទាំងអស់នេះ និងនៅមានការងារអាទិភាព ជាច្រើនទៀតដែលត្រូវធ្វើជាបន្តបន្ទាប់ ដើម្បីបម្រើប្រជាជនយើងឲ្យបានកាន់តែល្អប្រសើរជាងមុន។ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលកំពុងសិក្សា និងរៀបចំសេចក្តីព្រាងឯកសារទស្សនទានស្តីពី ប្រព័ន្ធគុណភាពសេវាសាធារណៈ ដែលមានចំណុចសំខាន់ៗ ចំនួន ០៤ គឺ ***ទី១****–ភាពងាយស្រួលនៃការចូលយកសេវារបស់ប្រជាជន* ***ទី២****–គុណភាពនៃព័ត៌មានសេវាសាធារណៈ ដែលផ្តល់ជូនប្រជាជន* ***ទី៣****–ភាពឆ្លើយតបនៃការផ្តល់សេវាជូនប្រជាជន និង*__*ទី៤*__*–យន្តការផ្តល់ព័ត៌មានត្រឡប់។*

សេវាសាធារណៈត្រូវតែប្រកបដោយគុណភាព តម្លាភាព មានតម្លៃថោកសមរម្យ (ក្នុងករណីសេវាត្រូវបង់ថ្លៃ) មានស្តង់ដាសមស្រប បែបបទ និងនីតិវិធីមានភាពសាមញ្ញ មិនស្មុគស្មាញ ហើយត្រូវផ្តោតលើតម្រូវការរបស់ប្រជាជន។ ដើម្បីសម្រេចបាននូវគោលបំណងទាំងនេះតម្រូវឲ្យមានការសិក្សា និងពិនិត្យរួមគ្នាលើបែបបទ នីតិវិធី នៃការផ្តល់សេវាសាធារណៈដែលកំពុងតែអនុវត្ត ដើម្បីធ្វើការកែលម្អជាបន្តបន្ទាប់។ កត្តាជោគជ័យឬមិនជោគជ័យ គឺអាស្រ័យលើសមត្ថភាពរបស់មន្ត្រីរាជការ និងស្ថាប័ន។ ដូចដែលឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន**

(តទៅទំព័រ ៨)

## សិក្ខាសាលា ស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅ......

កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលមានគោលដៅប្រែក្លាយរដ្ឋបាលសាធារណៈឲ្យក្លាយជាអ្នកផ្តល់សេវាដ៏ស័ក្តិសិទ្ធតាមរយៈយន្តការពីរដែលប្រទាក់ក្រឡាគ្នា និងបំពេញឲ្យគ្នាទៅវិញទៅមកគឺ **ទីមួយ**–ការធ្វើឲ្យរដ្ឋបាលសាធារណៈកាន់តែមាន តម្លាភាព ភាពឆ្លើយតប និងប្រសិទ្ធភាព និង **ទីពីរ**–ការលើកកម្ពស់ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ។ ដើម្បីសម្រេចបានគោលដៅនេះ ក៏ដូចជាដើម្បីភាពជោគជ័យនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល ធនធានមនុស្ស និងការចូលរួមរបស់មន្ត្រីរាជការស៊ីវិលគឺជាកត្តាសំខាន់ជាសារវ័ន្ត។ ប្រការនេះទាក់ទងដល់ការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការ ដែលជាការវិនិយោគមួយមានលក្ខណៈជាយុទ្ធសាស្ត្រ (ដោយផលចំណេញមានលក្ខណៈអរូបិយ និងប្រើប្រាស់រយៈពេលយូរ) និងដែលសំដៅដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារ (Performance) របស់មន្ត្រីរាជការតាមរយៈការបណ្តុះបណ្តាលបន្ត និងការអភិវឌ្ឍចំណេះដឹងជំនាញ និងបទពិសោធន៍ ដើម្បីធ្វើការផ្លាស់ប្តូរជាបណ្តើរៗនូវអាកប្បកិរិយា និងឥរិយាបថរបស់មន្ត្រីរាជការពី "អ្នកត្រួតត្រា" ទៅជា "អ្នកផ្តល់សេវា" ប្រកបដោយគុណភាព និងប្រសិទ្ធភាពជូនប្រជាពលរដ្ឋ។

អស់រយៈពេល ០៤ ថ្ងៃ សិក្ខាសាលាបានរួមចំណែកដល់ការអភិវឌ្ឍសមត្ថភាព ចំណេះដឹង និងជំនាញរបស់មន្ត្រីរាជការ ជាពិសេសទាក់ទងនឹងការផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងនានាពីសាស្ត្រាចារ្យបរទេសមកពីប្រទេសជប៉ុន ម៉ាឡេស៊ី និងសិង្ហបុរី លើការគ្រប់គ្រងរដ្ឋបាលសាធារណៈ ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ព្រមទាំងការលើកយកករណីសិក្សាលើបទពិសោធន៍ នៃប្រទេសមួយចំនួន (ជាពិសេសប្រទេសជប៉ុន និងសិង្ហបុរី) មកចែកជូនសិក្ខាកាមរបស់យើងដើម្បីប្រៀបធៀប និងស្វែងយល់ដូចជាទាក់ទងនឹងគោលនយោបាយឆ្លើយតប របស់រដ្ឋាភិបាលក្នុងពេលមានវិបត្តិ របៀបនៃការគ្រប់គ្រង និងបញ្ហាអភិបាលកិច្ចល្អជាដើម ។ល។

លើសពីនេះ ដោយភ្ជាប់ជាមួយនឹងបទពិសោធន៍ និងករណីសិក្សារបស់ប្រទេសមួយចំនួន សិក្ខាសាលានេះក៏ផ្តោតផងដែរលើប្រធានបទទី១ ស្តីពី "ការគ្រប់គ្រងវដ្តនៃគម្រោង" លើការរៀបចំជាគម្រោងដែលជាទុនក្នុងការអនុវត្ត និងស្រាវជ្រាវបន្ថែម និងប្រធានបទទី២ ស្តីពី "វិធីសាស្ត្ររៀបចំករណីសិក្សា" លើការណែនាំក្នុងការស្រាវជ្រាវ និងរៀបចំជាករណីសិក្សាលើបញ្ហានានា ដែលទាក់ទងនឹងរដ្ឋបាលសាធារណៈនៅកម្ពុជា សម្រាប់ជាឯកសារក្នុងការបង្រៀនបន្តនៅតាមក្រសួង ស្ថាប័ន និងសាលាបណ្តុះបណ្តាលនានា។

សិក្ខាសាលាបានបញ្ចប់ទៅដោយជោគជ័យនៅរសៀលថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១០ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ង៉ោ ហុងលី** អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងលោកបណ្ឌិត Akinori SEKI ប្រធានមូលនិធិសន្តិភាពសាសាកាវ៉ា ដោយមានចែកវិញ្ញាបនបត្រជូនសិក្ខាកាមដែលបានចូលរួមទាំង ០២ វគ្គផងដែរ។

## ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយ.....

មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ន ដែលអនុវត្តគម្រោង ឬកម្មវិធីអាទិភាពនានារបស់រាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ ដែលគាំទ្រដល់ការងារអាទិភាពនានានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

៣-ការកំណត់មុខសញ្ញាមន្ត្រី ឲ្យបំពេញការងារក្នុងគម្រោងចំណាយប្រតិបត្តិការអាទិភាព ត្រូវអនុវត្តឲ្យមានតម្លាភាព ដោយផ្អែកលើលក្ខខណ្ឌយោង លក្ខណសម្បត្តិសក្តិសម និងមានសមធម៌ ព្រមទាំងមាននីតិវិធី និងបែបបទជ្រើសរើសច្បាស់លាស់ ដែលមានចែងនៅក្នុងកិច្ចសន្យាគ្រប់គ្រង។ មន្ត្រីត្រូវចូលបម្រើការងារនៅក្រោយពេលមានប្រកាសតែងតាំងពីក្រសួង ស្ថាប័នពាក់ព័ន្ធ។

៤-ចំណាយប្រតិបត្តិការអាទិភាព គឺជាចំណាយសរុបប្រចាំខែ ដោយផ្អែកលើទិន្នផល ឬលទ្ធផលការងារក្នុងការគាំទ្រដល់កម្មវិធី គម្រោង ឬសកម្មភាពអាទិភាពនានា ហើយរាល់ការចំណាយនេះត្រូវធ្វើការសម្របសម្រួល និងធ្វើសុខដុមនីយកម្មឲ្យស្របទៅតាមបទដ្ឋានគោលដែលបានឯកភាពគ្នាសម្រាប់ប្រភេទនៃចំណាយជាក់ស្តែងនីមួយៗ។

៥-ការគ្រប់គ្រងចំណាយប្រតិបត្តិការអាទិភាពត្រូវផ្អែកតាមលក្ខណសម្បត្តិសក្តិសម និងមានតម្លាភាព ដោយប្រើប្រាស់លក្ខខណ្ឌយោងសម្រាប់មុខតំណែងជាបុគ្គល ជាក្រុម ឬជាអង្គភាពសេវាសាធារណៈជាគោលដៅ ព្រមទាំងមានកិច្ចសន្យារវាងអ្នកទទួលគម្រោង និងថ្នាក់ដឹកនាំរបស់ខ្លួន។ ក្នុងន័យនេះ អ្នកទទួលបានចំណាយប្រតិបត្តិការអាទិភាព ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ស្ថាប័នសាមី និងនៅបន្តភាពជាមន្ត្រីរាជការរបស់ក្រសួង ស្ថាប័ន ហើយទំនាក់ទំនងរបស់អ្នកទាំងនោះជាមួយដៃគូអភិវឌ្ឍគឺជាផ្នែកមួយនៃភាពជាដៃគូ ។

### ២. ឧបករណ៍ចំណាយប្រតិបត្តិការអាទិភាព

១. <u>និយមន័យនៃពាក្យ</u>

- ***ឧបករណ៍ចំណាយប្រតិបត្តិការអាទិភាព* (POC Instrument)** : ឧបករណ៍ចំណាយប្រតិបត្តិការអាទិភាព គឺជាឧបករណ៍បណ្តោះអាសន្នមួយ ដែលគាំទ្រដល់ការអនុវត្តកម្មវិធី ឬគម្រោងក្នុងក្របខណ្ឌសហប្រតិបត្តិការអភិវឌ្ឍ ដើម្បីរក្សាឲ្យបានតុល្យភាពរវាងសមធម៌ និងប្រសិទ្ធភាពការងារ។ ឧបករណ៍ចំណាយប្រតិបត្តិការអាទិភាពនឹងត្រូវបានធ្វើនិយ័តទៅតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងឯកសារណែនាំសម្រាប់ការអនុវត្តឧបករណ៍នេះ។
- ***គម្រោងចំណាយប្រតិបត្តិការអាទិភាព* (POC Schemes)** : គម្រោងចំណាយប្រតិបត្តិការអាទិភាព សំដៅលើចំណាយប្រតិបត្តិការអាទិភាពនីមួយៗ ដែលត្រូវបានបង្កើតឡើងតាមរយៈលក្ខខណ្ឌយោង កិច្ចសន្យាគ្រប់គ្រង និងកិច្ចព្រមព្រៀងសម្រាប់អនុវត្ត ស្របទៅនឹងឯកសារណែនាំសម្រាប់អនុវត្តនេះ។ គម្រោងចំណាយប្រតិបត្តិការអាទិភាពអាចមានលើសពីមួយនៅក្នុងក្រសួង ស្ថាប័នមួយ ឬវិស័យមួយ។ ប៉ុន្តែទៅថ្ងៃមុខមានការប៉ាន់ស្មានថាគម្រោងទាំងនេះនឹងត្រូវបញ្ចូលគ្នាទៅជាគម្រោងចំណាយប្រតិបត្តិការអាទិភាពតែមួយ។
- ***ការចំណាយសម្រាប់ចំណាយប្រតិបត្តិការអាទិភាព* (POC Payments )** : ការចំណាយសម្រាប់ចំណាយប្រតិបត្តិការអាទិភាព គឺជាប្រាក់ចំណាយ (ដែលជាទូទៅគិតជាប្រចាំខែ) ដែលមន្ត្រីបម្រើការងារក្នុងគម្រោងចំណាយប្រតិបត្តិការអាទិភាពទទួលបាន។ មន្ត្រីម្នាក់ៗត្រូវបានតែងតាំងឲ្យបម្រើការងារក្នុងគម្រោងតែមួយគត់ក្នុងពេលតែមួយ ហើយត្រូវទទួលបានប្រាក់ចំណាយប្រតិបត្តិការអាទិភាពតែមួយក្នុងពេលតែមួយ។ មន្ត្រីបម្រើការងារក្នុងគម្រោងនៅបន្តទទួលបានប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលជាធម្មតា។

(តទៅទំព័រ ៩)

## វគ្គបណ្តុះបណ្តាល ស្តីពី ការកែលម្អ.....

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ធ្លាប់មានប្រសាសន៍ថា ស្ថាប័នដែល មានតម្លាភាព ភាពឆ្លើយតប និងប្រសិទ្ធភាព និងទ្រទ្រង់ដោយ មន្ត្រីរាជការដែលបំពេញការងារប្រកបដោយ ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ គឺជាកត្តាដ៏សំខាន់ដើម្បីសម្រេចបានជោគជ័យតាម ការកំណត់។ ក្នុងស្មារតីនេះសមត្ថភាព ជំនាញ របស់ មន្ត្រីរាជការត្រូវបានពង្រឹងជាបន្តបន្ទាប់ ហើយផ្នត់គំនិត និង អាកប្បកិរិយាក៏ត្រូវតែផ្លាស់ប្តូរពី "អ្នកត្រួតត្រា" ទៅជា "អ្នក ផ្តល់សេវា"។ ក្រសួង ស្ថាប័នចាំបាច់ត្រូវគិតគូរពីតម្រូវការ របស់ ប្រជាជនជាជាងផ្តោតតែលើនីតិវិធីរដ្ឋបាល ហើយ ដំណើរការនៅគ្រប់ក្រសួង ស្ថាប័ន ត្រូវឈរលើគោលការណ៍ អភិបាលកិច្ចល្អ។ ដូច្នេះមានន័យថាសមត្ថភាពរបស់ មន្ត្រីរាជការ គឺជាកត្តាកំណត់ជោគជ័យ ហើយសមត្ថភាព របស់ស្ថាប័ននៃរដ្ឋបាលសាធារណៈ គឺជាកត្តាកំណត់ និរន្តរភាព។

## ការចុះសិក្សាស្វែងយល់លើការផ្តល់សេវាសាធារណៈវិស័យសុខាភិបាលនៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក មន្ទីរពេទ្យកុមារជាតិ និងមន្ទីរពេទ្យព្រះកុសុមៈ

ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ គឺជា គោលដៅអាទិភាពមួយដ៏សំខាន់នៅក្នុងកម្មវិធីជាតិកំណែ–ទម្រង់រដ្ឋបាលដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ និង កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ។

គោលដៅនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល គឺធ្វើ ទំនើបកម្មនៃរដ្ឋបាលសាធារណៈ ដើម្បីបម្រើប្រជាជន ឲ្យបានកាន់តែល្អប្រសើរឡើង ដោយប្រែក្លាយរដ្ឋបាល សាធារណៈឲ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងមាន ការជឿទុកចិត្តពីប្រជាជន។



ឯកឧត្តម ង៉ោ ហុងលី អគ្គលេខាធិការ នៃក្រុមប្រឹក្សា កំណែទម្រង់រដ្ឋបាល និងក្រុមការងារ រួមដំណើរដោយ តំណាងក្រសួងសុខាភិបាល ចុះសិក្សាស្វែងយល់ លើការផ្តល់សេវាសាធារណៈវិស័យសុខាភិបាលនៅ មជ្ឈមណ្ឌលគាំពារមាតា និងទារក

(តទៅទំព័រ ១១)

## ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយ.....

• **មុខតំណែងនៃគម្រោងចំណាយប្រតិបត្តិការអាទិភាព** *(POC Scheme Positions)* : មុខតំណែង នៃគម្រោងចំណាយប្រតិបត្តិការអាទិភាព គឺជាមុខតំណែងដែលត្រូវបានបង្កើតឡើងទៅតាមភាពជាក់ស្តែងនៃគម្រោង ឬកម្មវិធីអភិវឌ្ឍដែលគាំទ្រដោយដៃគូអភិវឌ្ឍ នៅក្នុងក្របខណ្ឌសហប្រតិបត្តិការអភិវឌ្ឍ។

• **លក្ខខណ្ឌយោង** *(Terms of Reference)* : លក្ខខណ្ឌយោង គឺជាឯកសារដែលពិពណ៌នាពីគោលបំណងនៃគម្រោងចំណាយប្រតិបត្តិការអាទិភាព ពីវិសាលភាព វត្ថុបំណង និងលទ្ធផលរំពឹងទុក ព្រមទាំងការស្នើឡើងពីរបទាសម្ព័ន្ធ និងការចំណាយនៃគម្រោង។

• **កិច្ចសន្យាគ្រប់គ្រង** *(Management Contract)*: កិច្ចសន្យាគ្រប់គ្រង គឺជាឯកសារដែលមានលម្អិតពីការព្រមព្រៀងរវាងក្រសួង ស្ថាប័នជាមួយនឹងនាយកកម្មវិធី ដើម្បីគ្រប់គ្រងទៅលើវិសាលភាព រចនាសម្ព័ន្ធ លទ្ធផលរំពឹងទុក ពេលវេលា និងលក្ខខណ្ឌនានានៃគម្រោងចំណាយប្រតិបត្តិការអាទិភាព។

• **ការព្រមព្រៀងអនុវត្ត** *(Implementation Agreement)* : ការព្រមព្រៀងអនុវត្ត គឺជាឯកសារដែលមានចែងលម្អិតពីការព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជាតំណាងដោយក្រសួង ស្ថាប័នសាមី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាមួយដៃគូអភិវឌ្ឍពាក់ព័ន្ធទៅលើការអនុវត្តគម្រោងចំណាយប្រតិបត្តិការអាទិភាព ក្នុងនោះមានចែងអំពីបញ្ហាការផ្តល់មូលនិធិ ការគ្រប់គ្រង ការត្រួតពិនិត្យឡើងវិញ ការធ្វើសវនកម្ម និងរយៈពេលនៃការអនុវត្តកិច្ចព្រមព្រៀង។

• **កិច្ចសន្យាការងារ** *(Personal Service Contract)* : កិច្ចសន្យាការងារ គឺជាកិច្ចសន្យារវាងនាយកកម្មវិធី ឬតំណាងដែលត្រូវបានធ្វើប្រតិភូកម្មជាមួយនឹងមន្ត្រីអនុវត្តគម្រោងម្នាក់ៗ ដោយកំណត់ទៅលើពេលវេលា និងលក្ខខណ្ឌផ្សេងៗនៃការតែងតាំងសម្រាប់គម្រោងចំណាយប្រតិបត្តិការអាទិភាព ដូចជារយៈពេលនៃកិច្ចសន្យា និងលទ្ធផលរំពឹងទុកដែលជាការទទួលខុសត្រូវរបស់មន្ត្រីគម្រោងម្នាក់ៗ។

• **ប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព** *(Performance Management and Accountability System)* : ប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព គឺជាប្រព័ន្ធមួយសម្រាប់គាំទ្រទៅលើដំណើរការគ្រប់គ្រង និងវាយតម្លៃលើសកម្មភាពការងាររបស់មន្ត្រីគម្រោងក្នុងការសម្រេចបេសកកម្ម និងវត្ថុបំណងនានានៃគម្រោងចំណាយប្រតិបត្តិការអាទិភាព។

**២.** <u>ចរិតលក្ខណៈសំខាន់ៗនៃចំណាយប្រតិបត្តិការអាទិភាព</u>

១- គម្រោងចំណាយប្រតិបត្តិការអាទិភាព ត្រូវបានបង្កើតឡើង និងគ្រប់គ្រងដោយផ្អែកតាមគោលការណ៍ ០៣ សំខាន់ គឺ សុខដុមនីយកម្ម ការកាត់តម្រឹម និងការកែតម្រូវ ដែលនេះមានន័យសំដៅដល់ការរក្សាឲ្យមានតុល្យភាពត្រឹមត្រូវរវាងប្រសិទ្ធភាពការងារ និងសមធម៌។

២- ការកែតម្រូវ (Adjustment) គឺសំដៅទៅលើការផ្តល់មូលនិធិប្រកបដោយតម្លាភាព និងសមធម៌សម្រាប់ទ្រទ្រង់ដល់ចំណាយប្រតិបត្តិការអាទិភាពនៅក្នុងមុខងារសាធារណៈ និងដើម្បីប្រើប្រាស់លទ្ធភាពនៃការផ្តល់មូលនិធិរបស់ដៃគូអភិវឌ្ឍប្រកបដោយសុទិដ្ឋិនិយម។ យន្តការនៃការកែតម្រូវ នឹងត្រូវរៀបចំឲ្យបានចប់សព្វគ្រប់នៅមុនដំណាច់ឆ្នាំ ២០១០ សម្រាប់ការអនុវត្តដំបូងទៅតាមការប្រកាសដាក់ឲ្យដំណើរការនូវឧបករណ៍ចំណាយប្រតិបត្តិការអាទិភាព។ រហូតមកដល់ពេលនេះ គោលការណ៍នៃការកែតម្រូវត្រូវបានពិចារណានៅ ក្នុងការរៀបចំបង្កើតកិច្ចព្រមព្រៀងសម្រាប់ការអនុវត្ត។

៣- មាត្រា៣នៃអនុក្រឹត្យ ស្តីពីការបង្កើត និងការដាក់ឲ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាពក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍចែងថា ចំណាយប្រតិបត្តិការ

(តទៅទំព័រ ១០)

## ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយ.....

អាទិភាព មិនមែនជាប្រាក់បៀវត្សឬជាប្រាក់ឧបត្ថម្ភបន្ថែមឡើយ។ ប្រាក់ឧបត្ថម្ភបន្ថែម គឺជាចំណាយសម្រាប់បន្ថែមទៅលើបៀវត្សរបស់មន្ត្រីរាជការ ដែលកំពុងបំពេញការងារទៅតាមតម្រូវការនៃមុខតំណែងនៅតាមក្រសួង ស្ថាប័ន។ ចំណាយប្រតិបត្តិការអាទិភាព គឺជាការចំណាយទៅលើការងារ នៅក្នុងបរិបទនៃសហប្រតិបត្តិការអភិវឌ្ឍ។

៤- នៅក្នុងបរិបទនៃកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍ ដៃគូអភិវឌ្ឍមិនអាចផ្តល់ជូនមន្ត្រីរាជការនូវចំណាយប្រតិបត្តិការណាមួយក្រៅពីចំណាយប្រតិបត្តិការអាទិភាពនេះឡើយ លើកលែងមានការអនុញ្ញាតជាផ្លូវការពីរាជរដ្ឋាភិបាល។ មន្ត្រីរាជការអាចត្រូវបានតែងតាំងតែមួយលើកគត់សម្រាប់គម្រោងចំណាយប្រតិបត្តិការអាទិភាពមួយក្នុងពេលតែមួយ។

៥- គម្រោងចំណាយប្រតិបត្តិការអាទិភាពអាចមានតែមួយនៅក្នុងក្រសួង ស្ថាប័នមួយ។ ប៉ុន្តែជាក់ស្តែងអាចមានគម្រោងចំណាយប្រតិបត្តិការអាទិភាពលើសពីមួយនៅតាមក្រសួង ស្ថាប័ន ដោយយោងតាមការព្រមព្រៀងរវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៦- ការបង្កើតគម្រោងចំណាយប្រតិបត្តិការអាទិភាព តម្រូវឲ្យមានលក្ខខណ្ឌយោង កិច្ចសន្យាគ្រប់គ្រងការពិពណ៌នាមុខតំណែង ការជ្រើសរើសដោយផ្អែកតាមលក្ខណសម្បត្តិសក្តិសម ផែនការការងារ កិច្ចសន្យាការងារ និងប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព។

៧- នាយកកម្មវិធីចំណាយប្រតិបត្តិការអាទិភាពនឹងត្រូវបានតែងតាំងមុនគេដោយក្រសួង ឬប្រធានស្ថាប័ន នៅក្នុងដំណើរការអនុវត្ត ដើម្បីសម្រួលដល់ការរៀបចំរចនាសម្ព័ន្ធគម្រោង និងការបង្កើតកិច្ចសន្យាគ្រប់គ្រងសម្រាប់ឆ្លើយតបនឹងតម្រូវការរបស់ កម្មវិធី ឬគម្រោង។

៨- នាយកកម្មវិធីចំណាយប្រតិបត្តិការអាទិភាពនឹងមានគណនេយ្យភាពចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងគម្រោង និងទទួលខុសត្រូវដោយផ្ទាល់ចំពោះអំពើល្មើស ឬអំពើពុករលួយនៅក្នុងការជ្រើសរើសមន្ត្រីឲ្យបំពេញការងារក្នុងគម្រោង។

៩- តារាងចំណាយត្រូវចែកឲ្យមានខ្ទង់ជាចំនួនទឹកប្រាក់សរុបទៅតាមប្រភេទមុខតំណែងនីមួយៗនៅក្នុងគម្រោង ឬកម្មវិធីអភិវឌ្ឍដែលគាំទ្រដោយដៃគូអភិវឌ្ឍ ។

១០- មន្ត្រីដែលតែងតាំងក្នុងគម្រោងចំណាយប្រតិបត្តិការអាទិភាពទទួលប្រាក់ចំណាយដោយផ្អែកតាមការងាររបស់ខ្លួនដែលមានកំណត់នៅក្នុងកិច្ចសន្យាគ្រប់គ្រង និងការពិពណ៌នាមុខតំណែង។ ការផ្តល់ប្រាក់ចំណាយសម្រាប់អ្នកដែលត្រូវបានតែងតាំងក្នុងគម្រោងចំណាយប្រតិបត្តិការអាទិភាព នឹងត្រូវចាត់ចែងដោយនាយកកម្មវិធីចំណាយប្រតិបត្តិការអាទិភាព នឹងត្រូវផ្អែកទៅលើតារាងចំណាយប្រតិបត្តិការអាទិភាព។ មន្ត្រីបម្រើការងារក្នុងគម្រោងចំណាយប្រតិបត្តិការអាទិភាព អាចទទួលបាននូវការចំណាយស្របតាមអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុង និងក្រៅប្រទេស និងការចំណាយផ្សេងៗទៀតទៅតាមបញ្ញត្តិច្បាប់របស់រាជរដ្ឋាភិបាល ។

១១- ប្រាក់ចំណាយ នឹងត្រូវបានផ្តល់ដោយផ្ទាល់ចូលទៅក្នុងគណនីធនាគាររបស់មន្ត្រីបម្រើការងារក្នុងគម្រោងជាប្រចាំខែ ដោយផ្អែកលើការសម្រេចបានលទ្ធផលរំពឹងទុកដែលមានកំណត់ក្នុងកិច្ចសន្យាការងារ ហើយការចំណាយនេះនឹងត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវសម្រាប់ការធ្វើសវនកម្ម។

១២- ប្រាក់ចំណាយត្រូវបញ្ចប់នៅពេលលទ្ធផលរំពឹងទុកត្រូវបានសម្រេច ឬកម្មវិធី ឬគម្រោងសហប្រតិបត្តិការអភិវឌ្ឍត្រូវបានបញ្ចប់។

១៣- ក្រសួង ស្ថាប័ន ទទួលខុសត្រូវក្នុងការបង្កើត ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យគម្រោងចំណាយប្រតិបត្តិការអាទិភាព នៅក្នុងយុត្តាធិការរបស់ខ្លួន។ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងសេដ្ឋកិច្ច និង

(តទៅទំព័រ ១២)

## ការចុះសិក្សាស្វែងយល់លើការផ្តល់សេវាសាធារណៈវិស័យ ....

ក្នុងបរិបទនេះ ការកែលម្អការផ្តល់សេវាសាធារណៈវិស័យសុខាភិបាលជូនប្រជាជនឲ្យកាន់តែមានគុណភាព និងបង្កលក្ខណៈងាយស្រួលដល់ប្រជាជនដែលមកទទួលយកសេវាពិនិត្យ និងព្យាបាលជំងឺ គឺជាកត្តាចាំបាច់បំផុតមិនអាចមើលរំលងបានឡើយ។

ក្នុងគោលដៅកែលម្អការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើងនេះ នៅព្រឹកថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកឧត្តម **ង៉ោ ហុងលី** អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រុមការងាររួមដំណើរដោយឯកឧត្តម **កើត មៀច** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល បានចុះទៅសិក្សាស្វែងយល់លើការផ្តល់សេវាវិស័យសុខាភិបាលជូនប្រជាពលរដ្ឋនៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក មន្ទីរពេទ្យកុមារ-ជាតិ និងមន្ទីរពេទ្យព្រះកុសុមៈ។



សកម្មភាពប្រជាពលរដ្ឋមកទទួលយកសេវាពិនិត្យសុខភាពកុមារ
នៅមន្ទីរពេទ្យកុមារជាតិ

ក្រោយពីបានពិនិត្យនៅមន្ទីរពេទ្យទាំង៣ រួចមក ឯកឧត្តម **ង៉ោ ហុងលី** បានវាយតម្លៃខ្ពស់ និងថ្លែងការកោតសរសើរដល់លោក លោកស្រី វេជ្ជបណ្ឌិត គ្រូពេទ្យ និងបុគ្គលិកបំរើការងារទាំងអស់ ដែលបានខិតខំប្រឹងប្រែងពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋអស់ពីកម្លាំងកាយកម្លាំងចិត្ត។

ក្នុងក្របខ័ណ្ឌនៃការពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឲ្យបានកាន់តែល្អប្រសើរឡើង ឯកឧត្តមក៏បានសំណូមពរឲ្យដល់មជ្ឈមណ្ឌល និងមន្ទីរពេទ្យទាំងអស់នូវចំណុចមួយចំនួន ដូចខាងក្រោម :

- សូមឲ្យកែលម្អកន្លែងទទួល និងផ្តល់ព័ត៌មានជូនប្រជាពលពលរដ្ឋឲ្យបានល្អថែមទៀត
- សូមឲ្យបិទផ្សាយតារាងតម្លៃសេវាជូនប្រជាពលរដ្ឋជាផ្ទាំងក្តារខៀនធំៗ
- សូមឲ្យបង្កើតប្រអប់ផ្តល់ព័ត៌មានត្រឡប់ពីប្រជា-ពលរដ្ឋដែលមកទទួលសេវាពិនិត្យ និងព្យាបាលជម្ងឺ
- សូមឲ្យកែសម្រួលប្រព័ន្ធការងារដើម្បីកាត់បន្ថយពេលវេលារង់ចាំរបស់ប្រជាពលរដ្ឋដែលមកទទួលសេវាពិនិត្យ និងព្យាបាលជម្ងឺ
- បំរើប្រជាជនឲ្យបានកាន់តែល្អប្រសើរឡើងតម្រូវឲ្យមន្ត្រីបរើការងារមានភាពរាក់ទាក់ ទន់ភ្លន់ និងយកចិត្តទុកដាក់ដល់ប្រជាជនដែលមកទទួលយកសេវា ។

ផ្ទៀតក្នុងឱកាសនោះ ឯកឧត្តមអគ្គលេខាធិការក៏បានចែកជូននូវកូនសៀវភៅគោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ និងកូនសៀវភៅគុណសម្បត្តិ នៃឥរិយាបថរបស់មន្ត្រីរាជការផងដែរ សម្រាប់ជាជំនួយស្មារតី និងជាមូលដ្ឋានកែលម្អអាកប្បកិរិយា និងឥរិយាបថរបស់មន្ត្រីរាជការ ឲ្យក្លាយខ្លួនពិតប្រាកដទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព។

## ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយ.....

ហិរញ្ញវត្ថុ ទទួលខុសត្រូវក្នុងការអនុម័តយល់ព្រមលើឯកសារព្រមព្រៀងអនុវត្តសម្រាប់គម្រោងចំណាយប្រតិបត្តិការអាទិភាព។ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យលើប្រសិទ្ធភាពនៃឧបករណ៍ចំណាយប្រតិបត្តិការអាទិភាពនេះ។

### គ. ដំណើរការអនុវត្តចំណាយប្រតិបត្តិការអាទិភាព

I. ការបង្កើត

**១.** ការកំណត់លក្ខខណ្ឌយោង

ការកំណត់លក្ខខណ្ឌយោង នៃគម្រោងចំណាយប្រតិបត្តិការអាទិភាព គឺជាការកំណត់ពីគោលបំណង វិសាលភាព និងរចនាសម្ព័ន្ធរបស់គម្រោងចំណាយប្រតិបត្តិការអាទិភាព។ លក្ខខណ្ឌយោង ត្រូវបានរៀបចំឡើងដោយក្រសួង ស្ថាប័ន ដោយមានជំនួយពីដៃគូអភិវឌ្ឍពាក់ព័ន្ធ ។

ឯកសារលក្ខខណ្ឌយោង រួមមាន :

១- បេសកកម្ម និងគោលបំណងរបស់គម្រោង គឺត្រូវពិពណ៌នាពីការងាររបស់គម្រោងចំណាយប្រតិបត្តិការអាទិភាព ដែលគាំទ្រទៅនឹងការងារអាទិភាពជាយុទ្ធសាស្ត្រស្នូលរបស់ក្រសួង ស្ថាប័ន។ ចំនុចនេះគួរ :

- យោងទៅលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- យោងទៅលើផែនការយុទ្ធសាស្ត្រ ឬផែនការប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន
- យោងទៅលើឯកសារក្របខ័ណ្ឌសហប្រតិបត្តិការនៃការអភិវឌ្ឍ។

២- កាលបរិច្ឆេទនៃការចាប់ផ្តើម និងការបញ្ចប់នៃគម្រោងចំណាយប្រតិបត្តិការអាទិភាព

៣- វត្ថុបំណង និងលទ្ធផលរំពឹងទុកដែលនឹងសម្រេចបានតាមរយៈគម្រោងចំណាយប្រតិបត្តិការអាទិភាព និងសូចនាករតាមដានត្រួតពិនិត្យ

៤- ការប៉ាន់ស្មានលើចំនួន និងប្រភេទមុខតំណែងដែលនឹងមាននៅក្នុងគម្រោងចំណាយប្រតិបត្តិការអាទិភាព ហើយជាទូទៅ គម្រោងចំណាយប្រតិបត្តិការអាទិភាពនឹងត្រូវ :

- ដឹកនាំដោយនាយកកម្មវិធីមួយរូប ដែលទទួលខុសត្រូវចំពោះរដ្ឋមន្ត្រី ឬប្រធានស្ថាប័នលើប្រសិទ្ធភាពការងាររបស់គម្រោងចំណាយប្រតិបត្តិការអាទិភាព និងផ្តល់លទ្ធផលជាក់លាក់
- មានប្រធានគម្រោងមួយ ឬច្រើន (អាស្រ័យទៅតាមទំហំនៃគម្រោង) ដែលនឹងទទួលខុសត្រូវចំពោះមុខនាយកកម្មវិធីគម្រោងចំណាយប្រតិបត្តិការអាទិភាព លើការផ្តល់នូវលទ្ធផលទៅតាមផែនការការងារ
- មានការទទួលខុសត្រូវ ទៅតាមមុខតំណែងនីមួយៗ សម្រាប់អនុវត្តផែនការសកម្មភាព និងការផ្តល់លទ្ធផលការងាររបស់មន្ត្រីម្នាក់ៗ។

៥- ការប៉ាន់ស្មានលើចំណាយសម្រាប់ប្រតិបត្តិការគម្រោង និង

៦- សេចក្តីសង្ខេបផែនការអនុវត្តដោយមានបញ្ជាក់ពីសកម្មភាពចម្បងៗសម្រាប់ការអនុវត្ត និងការកំណត់ពេលវេលា។

លក្ខខណ្ឌយោងនៃគម្រោងចំណាយប្រតិបត្តិការអាទិភាព នឹងត្រូវបានពិភាក្សានៅក្នុងក្របខ័ណ្ឌនៃក្រុមការងារបច្ចេកទេសតាមវិស័យ ដែលមានគម្រោងចំណាយប្រតិបត្តិការអាទិភាពអនុវត្ត ។ ប្រការនេះ គឺដើម្បីធានាឲ្យមានតម្លាភាព និងការសម្របសម្រួល និងជៀសវាងការជាន់ការងារគ្នា។

(គំរូនៃលក្ខខណ្ឌយោងមាននៅក្នុងឧបសម្ព័ន្ធទី១)

**២.** ការកំណត់រចនាសម្ព័ន្ធ និងដំណើរការគ្រប់គ្រង

ក្រសួង ស្ថាប័ន ត្រូវរៀបចំឲ្យមានរចនាសម្ព័ន្ធរបស់គម្រោងចំណាយប្រតិបត្តិការអាទិភាព ដោយកំណត់ពីទំនាក់ទំនងនៃការផ្តល់របាយការណ៍ និងដំណើរការនានាដែលជាតម្រូវការសម្រាប់ការអនុវត្ត និងប្រតិបត្តិការរបស់គម្រោង

(តទៅទំព័រ ១៣)

## ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយ.....

ចំណាយប្រតិបត្តិការអាទិភាព។ រចនាសម្ព័ន្ធ និងដំណើរការទាំងនេះនឹងមានលម្អិតនៅក្នុងកិច្ចសន្យាគ្រប់គ្រង ដែលរួមមាន :

ក) ការពិពណ៌នាមុខតំណែង និងលក្ខខណ្ឌវិនិច្ឆ័យនៃការជ្រើសរើសសម្រាប់មុខតំណែងនីមួយៗ : ក្រសួង ស្ថាប័នអាចប្រើប្រាស់គំរូនៃការពិពណ៌នាមុខតំណែងរបស់គម្រោងចំណាយប្រតិបត្តិការអាទិភាព (សូមមើលឧបសម្ព័ន្ធទី២) ឬអាចបង្កើត, ប្រើប្រាស់គំរូផ្ទាល់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ខ្លួន។

ខ) នីតិវិធីនៃការជ្រើសរើស និងការតែងតាំង ក្រសួង ស្ថាប័នត្រូវ :

- បង្កើតឲ្យមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការតែងតាំងក្នុងតំណែងនីមួយៗ
- រៀបចំបង្កើតនីតិវិធីជ្រើសរើស ដើម្បីជ្រើសរើសបេក្ខជនដែលសក្តិសមបំផុត ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់
- អាចបង្ហាញភស្តុតាងត្រឹមត្រូវចំពោះរាល់ការតែងតាំងទាំងអស់

គ) ប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព

- ធានាថា សកម្មភាពរបស់មន្ត្រីតែងតាំងក្នុងគម្រោង ត្រូវផ្អែកទៅលើការសម្រេចឲ្យបាននូវបេសកកម្ម និងវត្ថុបំណង នៃគម្រោងចំណាយប្រតិបត្តិការអាទិភាព
- ត្រូវផ្តល់វត្ថុបំណងច្បាស់លាស់ និងមានការព្រមព្រៀងលើលទ្ធផលរំពឹងទុកចំពោះមន្ត្រីដែលបានតែងតាំងក្នុងគម្រោង
- ជំរុញឲ្យមានប្រសិទ្ធភាពដល់ការតាមដានត្រួតពិនិត្យលើវឌ្ឍនភាពការងារ ដោយផ្ទៀបនឹងវត្ថុបំណងនៃគម្រោងចំណាយប្រតិបត្តិការអាទិភាព និងធានាឲ្យការចំណាយនៃគម្រោងចំណាយប្រតិបត្តិការអាទិភាពផ្សារភ្ជាប់នឹងលទ្ធផលការងារ និងការពង្រឹងវិធីសាស្ត្រគ្រប់គ្រងដោយផ្អែកលើលទ្ធផលការងារ។ (មានលម្អិតនៅក្នុងឧបសម្ព័ន្ធទី៣)

ឃ) នីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុ

- ការគ្រប់គ្រងមូលនិធិនៃចំណាយប្រតិបត្តិការអាទិភាព ត្រូវធ្វើតាមរយៈគណនីធនាគារ
- ការចំណាយនីមួយៗ នៃចំណាយប្រតិបត្តិការអាទិភាព ត្រូវផ្តល់ដោយផ្ទាល់ទៅក្នុងគណនីធនាគាររបស់មន្ត្រីដែលបានតែងតាំងក្នុងគម្រោង។ ជាទូទៅបើកជាប្រចាំខែ ដោយផ្អែកលើការសម្រេចបានតាមលក្ខខណ្ឌវិនិច្ឆ័យនៃប្រសិទ្ធភាពការងារដែលបានព្រមព្រៀងជាមុន និង
- ធានាឲ្យការចំណាយនីមួយៗត្រូវបានរក្សាទុកត្រឹមត្រូវសម្រាប់សវនកម្ម។

ង) ប្រព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍

- ផ្តល់របាយការណ៍ជាទៀងទាត់ចំពោះលទ្ធផលនៃការវាយតម្លៃ និងការតាមដានត្រួតពិនិត្យលើលទ្ធផលការងាររបស់គម្រោងចំណាយប្រតិបត្តិអាទិភាពទៅឲ្យក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងក្រុមការងារបច្ចេកទេសពាក់ព័ន្ធ
- របាយការណ៍នេះនឹងត្រូវបានប្រើប្រាស់សម្រាប់កំណត់ពីប្រសិទ្ធភាពការងាររបស់គម្រោងចំណាយប្រតិបត្តិការអាទិភាព និងដើម្បីមានលទ្ធភាពក្នុងការធ្វើការសម្រេចចិត្តទៅលើការបន្តអនុវត្តគម្រោង។

### ៣. ការរៀបចំកិច្ចសន្យាគ្រប់គ្រង

កិច្ចសន្យាគ្រប់គ្រង គឺជាកិច្ចសន្យារវាងនាយកកម្មវិធីចំណាយប្រតិបត្តិការអាទិភាពជាមួយនឹងក្រសួង ស្ថាប័នក្នុងការពង្រីកវិសាលភាពនៃលក្ខខណ្ឌយោង ហើយកិច្ចសន្យានេះអាចធ្វើការពិនិត្យឡើងវិញជាប្រចាំដោយយោងទៅតាមវឌ្ឍនភាពការងារ។ កិច្ចសន្យាគ្រប់គ្រងនេះ កំណត់នូវចំនុចមួយចំនួនដូចខាងក្រោម ដើម្បីផ្តល់ជាការពិពណ៌នាលម្អិតលើវិធីដែលគម្រោងចំណាយប្រតិបត្តិការអាទិភាពនឹងត្រូវសម្រេចឲ្យបាននូវបេសកកម្ម និងវត្ថុបំណងរបស់

(តទៅទំព័រ ១៤)

## ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយ.....

ខ្លួន :

- បេសកកម្ម និងវត្ថុបំណងរបស់គម្រោងចំណាយប្រតិបត្តិការអាទិភាព
- លទ្ធផលរំពឹងទុក និងសូចនាករតាមដានត្រួតពិនិត្យ
- មុខតំណែង និងអង្គការលេខរបស់គម្រោងចំណាយប្រតិបត្តិការអាទិភាព
- ការកំណត់នៃនីតិវិធីនានាក្នុងការជ្រើសរើស និងការតែងតាំង
- នីតិវិធីសម្រាប់ការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាពរបស់បុគ្គល/ក្រុម
- នីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុ និងថវិកាសម្រាប់ប្រតិបត្តិការ
- ប្រព័ន្ធនៃការរាយការណ៍ ការវាយតម្លៃ និងការតាមដានត្រួតពិនិត្យ នៃគម្រោងចំណាយប្រតិបត្តិការអាទិភាព
- ការកំណត់ផែនការអនុវត្តនៃគម្រោងចំណាយប្រតិបត្តិការអាទិភាព។ (សូមអានឧបសម្ព័ន្ធទី ៤)

### ៤. ការស្នើសុំអនុម័តជាគោលការណ៍

ក្រសួង ស្ថាប័ន នឹងស្នើសុំការអនុម័តយល់ព្រមជាគោលការណ៍ពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើឯកសារ:

- លក្ខខណ្ឌយោង
- កិច្ចសន្យាគ្រប់គ្រង

ឯកសារទាំងនេះត្រូវដាក់ស្នើទៅក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យបានឆាប់តាមដែលអាចធ្វើទៅបានដើម្បីសុំការអនុម័តឲ្យបានទាន់ពេលវេលា។ ការអនុម័តនេះគឺធ្វើឡើងតាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្រាប់ការអនុវត្ត។

### ៥. ការចុះហត្ថលេខាលើឯកសារព្រមព្រៀងសម្រាប់ការអនុវត្ត

ឯកសារព្រមព្រៀងសម្រាប់ការអនុវត្ត គឺជាការព្រមព្រៀងដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធបណ្តាដៃគូអភិវឌ្ឍដែលគាំទ្រគម្រោងចំណាយប្រតិបត្តិការអាទិភាព ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការព្រមព្រៀងនេះត្រូវបញ្ជាក់ពី :

- ចំនួន និងប្រភេទនៃមុខតំណែងដែលមានក្នុងគម្រោងចំណាយប្រតិបត្តិការអាទិភាព និងរចនាសម្ព័ន្ធគ្រប់គ្រង
- ការចំណាយប្រតិបត្តិការ និងយន្តការនៃការផ្តល់មូលនិធិ
- ដំណើរការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងតម្រូវការនៃការផ្តល់របាយការណ៍

ឯកសារព្រមព្រៀងការអនុវត្តនេះ ត្រូវភ្ជាប់ជាមួយនូវឯកសារពីរ ដូចខាងក្រោម :

- លក្ខខណ្ឌយោង និង
- កិច្ចសន្យាគ្រប់គ្រង

ឯកសារព្រមព្រៀងការអនុវត្តនេះ អាចយកទម្រង់តាមការព្រមព្រៀងជាក់ស្តែង អនុស្សរណៈនៃការយោគយល់ ឬការព្រមព្រៀងផ្តល់មូលនិធិរបស់ដៃគូអភិវឌ្ឍដែលមានស្រាប់។ សេចក្តីណែនាំគំរូសម្រាប់ការព្រមព្រៀងការអនុវត្តមាននៅក្នុងឧបសម្ព័ន្ធទី៥។

### ៦. ការជ្រើសរើសមន្ត្រី

ក្រសួង ស្ថាប័ន ត្រូវប្រើប្រាស់នីតិវិធីជ្រើសរើស និងការតែងតាំងដែលបានកំណត់នៅក្នុងកិច្ចសន្យាគ្រប់គ្រង ដើម្បីកំណត់មុខសញ្ញាមន្ត្រីសម្រាប់តែងតាំងក្នុងមុខតំណែងនីមួយៗនៃចំណាយប្រតិបត្តិការអាទិភាព។ នីតិវិធីនៃការជ្រើសរើស និងតែងតាំងនេះនឹងត្រូវបានប្រើប្រាស់ផងដែរសម្រាប់ការជ្រើសរើសបំពេញបន្ថែមក្នុងមុខតំណែងដែលទំនេរនៅក្នុងប្រតិបត្តិការនៃគម្រោងចំណាយប្រតិបត្តិការអាទិភាព។

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល អាចធ្វើអធិការកិច្ចទៅលើដំណើរការជ្រើសរើស ដើម្បីធានាថាដំណើរការ

(តទៅទំព័រ ១៥)

## ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយ.....

ជ្រើសរើសបានអនុវត្តទៅតាមបទដ្ឋាននៃតម្លាភាព ហើយការជ្រើសរើសបានផ្អែកទៅលើលក្ខណសម្បត្តិសក្តិសម។ នាយកកម្មវិធី ត្រូវមានគណនេយ្យភាពចំពោះមុខច្បាប់នូវរាល់បាតុភាពមួយ ចំនួនពាក់ព័ន្ធទៅនឹងការជ្រើសរើសនេះ។ កាលណាកម្មវិធីចំណាយប្រតិបត្តិការអាទិភាព គ្របដណ្តប់ទៅលើក្រសួង ស្ថាប័នច្រើនជាងពីការទទួលខុសត្រូវអាចធ្វើប្រតិភូកម្មទៅឲ្យនាយករងកម្មវិធី ឬប្រធានគម្រោងនៅតាមក្រសួង ស្ថាប័ននីមួយៗ។

**៧.** ការចេញប្រកាសតែងតាំង

នៅពេលដែលការតែងតាំងត្រូវបានអនុម័តយល់ព្រមដោយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ប្រកាសនឹងត្រូវបាន ដាក់ចេញដើម្បីបញ្ជាក់ពីការតែងតាំងបេក្ខជនដែលត្រូវបម្រើការងារនៅក្នុងគម្រោងចំណាយប្រតិបត្តិការអាទិភាព។ សេចក្តីចម្លងនៃសេចក្តីប្រកាសនេះនឹងត្រូវបានផ្ញើជូនទៅក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរក្សាទុកជាឯកសារ ។

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល នឹងបង្កើតជាប្រព័ន្ធទិន្នន័យមួយដើម្បីកត់ត្រារាល់គម្រោងចំណាយប្រតិបត្តិការអាទិភាពទាំងអស់ ព្រមទាំងរាល់មន្ត្រីទាំងអស់ដែលត្រូវបានតែងតាំងសម្រាប់គម្រោងចំណាយប្រតិបត្តិការអាទិភាព។

II. ការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព

១). បង្កើតផែនការការងារ នៃគម្រោងចំណាយប្រតិបត្តិការអាទិភាព

នាយកកម្មវិធី និងប្រធានគម្រោងចំណាយប្រតិបត្តិការអាទិភាពនឹងរៀបចំបង្កើតជាផែនការការងារសម្រាប់គម្រោងចំណាយប្រតិបត្តិការអាទិភាពជាប្រចាំឆ្នាំដោយផ្អែកលើលក្ខខណ្ឌយោង និងកិច្ចសន្យាគ្រប់គ្រង។ ផែនការការងារនេះនឹងកំណត់ពីសកម្មភាពនានា លទ្ធផលរយៈពេលខ្លី និងសូចនាករតាមដានសម្រាប់រយៈពេលដែលបានកំណត់ ហើយវានឹងក្លាយជាមូលដ្ឋានសម្រាប់កំណត់ពីការទទួលខុសត្រូវរវាងមន្ត្រីដែលបានតែងតាំងក្នុងគម្រោង និងសម្រាប់ការធ្វើរបាយការណ៍ពីលទ្ធផលនិងវឌ្ឍនភាពការងាររបស់គម្រោងចំណាយប្រតិបត្តិការអាទិភាព ។

២). បង្កើតកិច្ចសន្យាការងារ

រាល់មន្ត្រីដែលបានតែងតាំងសម្រាប់គម្រោងចំណាយប្រតិបត្តិការអាទិភាព ត្រូវចុះហត្ថលេខាលើកិច្ចសន្យាការងារជាមួយនឹងនាយកកម្មវិធី/តំណាងដែលត្រូវបានធ្វើប្រតិភូកម្មគម្រោងចំណាយប្រតិបត្តិការអាទិភាព។ កិច្ចសន្យានេះមានចែងអំពីលក្ខខណ្ឌ និងការកំណត់នៃការតែងតាំងដោយរួមបញ្ចូលទាំងរយៈពេលនៃកិច្ចសន្យាផង។ កិច្ចសន្យាការងារនឹងមានកំណត់ផងដែរអំពីសកម្មភាពនានា លទ្ធផលរំពឹងទុក សូចនាករ ព្រមទាំងរយៈពេលកំណត់ដែលនឹងត្រូវប្រើប្រាស់ជាមូលដ្ឋាននៃការវាយតម្លៃលើប្រសិទ្ធភាពការងារ។ សកម្មភាព និងលទ្ធផលរំពឹងទុកទាំងនេះអាចត្រូវបានកំណត់លម្អិតសម្រាប់មន្ត្រីគម្រោងម្នាក់ៗ ឬសម្រាប់ក្រុមអាស្រ័យទៅតាមប្រភេទ នៃសកម្មភាពដែលត្រូវបំពេញ និងលទ្ធផលដែលត្រូវសម្រេច។

៣). វាយតម្លៃជាប្រចាំ

ជាប្រចាំយ៉ាងតិច ០៦ ខែម្តង មន្ត្រីគម្រោងម្នាក់ៗ ត្រូវចូលរួមប្រជុំជាមួយនឹងនាយកកម្មវិធី/ប្រធានគម្រោង ដើម្បីពិនិត្យឡើងវិញលើវឌ្ឍនភាពការងារ ធៀបជាមួយនឹងកិច្ចសន្យាការងាររបស់ខ្លួន។ ការពិនិត្យឡើងវិញលើវឌ្ឍនភាពការងារនេះ នឹងត្រូវបានប្រើប្រាស់សម្រាប់ :

- តាមដាន ត្រួតពិនិត្យវឌ្ឍនភាពការងារជាមួយនឹងលទ្ធផលរំពឹងទុក
- ពិនិត្យឡើងវិញលើលទ្ធផលរំពឹងទុកទៅតាមការចាំបាច់
- វាយតម្លៃលើភាពស៊ីសង្វាក់គ្នាជាមួយនឹងការកំណត់របស់កិច្ចសន្យាដទៃទៀត និង

( តទៅទំព័រ ១៦)

## ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយ.....

• ផ្តល់ព័ត៌មានត្រឡប់ និងចាត់វិធានការកែតម្រូវទៅតាមការចាំបាច់ ។

នៅពេលបញ្ចប់កិច្ចសន្យាការងារ ប្រសិទ្ធភាពការងាររបស់មន្ត្រីគម្រោងនឹងត្រូវបានវាយតម្លៃដោយធៀបជាមួយនឹងការកំណត់នៅក្នុងកិច្ចសន្យាការងាររបស់មន្ត្រីម្នាក់ៗ នៅក្នុងកិច្ចប្រជុំជាមួយនឹងអ្នកគ្រប់គ្រង។ ការវាយតម្លៃលើប្រសិទ្ធភាពការងារនេះនឹងត្រូវបានប្រើប្រាស់ដើម្បី :

• វាយតម្លៃលើការសម្រេចបានតាមលទ្ធផលរំពឹងទុក

• វាយតម្លៃលើភាពស៊ីសង្វាក់គ្នាជាមួយនឹងការកំណត់របស់កិច្ចសន្យាដទៃទៀត

• ពិចារណាលើការបន្តកិច្ចសន្យាការងារថ្មី (ប្រសិនបើគម្រោងចំណាយប្រតិបត្តិការអាទិភាពនេះត្រូវបន្ត)

កិច្ចសន្យាគ្រប់គ្រងនឹងកំណត់អំពីនីតិវិធីនៃការវាយតម្លៃលើប្រសិទ្ធភាពការងារ។

រូបភាពទី១ : វដ្តនៃប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព




*តម្រូវការនៃប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យមានកំណត់ក្នុងឧបសម្ព័ន្ធទី៣ ហើយគំរូនៃកិច្ចសន្យាការងារមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៦ ។*

### II. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

#### ១. ការធ្វើរបាយការណ៍ និងការវាយតម្លៃជាប្រចាំ

ក្រសួង ស្ថាប័នមានតួនាទីសំខាន់គឺ ដឹកនាំ និងមានម្ចាស់ការលើគម្រោងចំណាយប្រតិបត្តិការអាទិភាពនៅក្នុងយុត្តាធិការរបស់ខ្លួន។ ក្រសួង ស្ថាប័នត្រូវផ្តល់ការចង្អុលបង្ហាញច្បាស់លាស់ដល់នាយកកម្មវិធីគម្រោងចំណាយប្រតិបត្តិការអាទិភាព ត្រូវតាមដានត្រួតពិនិត្យឲ្យបានដិតដល់លើប្រសិទ្ធភាពការងារ ព្រមទាំងផ្តល់ជាធនធាន និងការគាំទ្រដែលចាំបាច់ ដើម្បីសម្រេចវត្ថុបំណងរបស់ខ្លួន។ ប្រព័ន្ធនៃការតាមដានត្រួតពិនិត្យដែលមានលក្ខណៈជាក់ស្តែង ឆ្លើយតបទាន់ពេលវេលា និងមានប្រសិទ្ធភាព គឺជាកត្តាសំខាន់ដើម្បីសម្រេចបានវត្ថុបំណងរបស់បុគ្គល និងស្ថាប័ន។ ប្រព័ន្ធនេះជាឧបករណ៍ដែលមានប្រសិទ្ធភាពក្នុងការអនុវត្តការផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបថ។

នាយកកម្មវិធីចំណាយប្រតិបត្តិការអាទិភាព នឹងធ្វើរបាយការណ៍ជាប្រចាំអំពីវឌ្ឍនភាពការងារ (ជាទូទៅ ០៦ ខែម្តង) ដោយផ្តោតទៅលើបញ្ហាសំខាន់ និងឧបសគ្គនានា សមិទ្ធផលនៃផែនការការងាររបស់គម្រោងចំណាយប្រតិបត្តិការអាទិភាព និងកិច្ចសន្យាគ្រប់គ្រង សំណើក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារ និងសមធម៌ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុ។ នៅចុងបញ្ចប់នៃគម្រោងចំណាយប្រតិបត្តិការអាទិភាព ការវាយតម្លៃជាទ្រង់ទ្រាយធំលើគម្រោងទាំងមូលនឹងត្រូវបានធ្វើឡើង ហើយរបាយការណ៍នៃការវាយតម្លៃនឹងត្រូវផ្សព្វផ្សាយ។

តម្រូវការនៃការតាមដានត្រួតពិនិត្យ វាយតម្លៃ និងផ្តល់របាយការណ៍ មានកំណត់នៅក្នុងកិច្ចសន្យាគ្រប់គ្រងដែលបានធ្វើឡើងរវាងនាយកកម្មវិធីចំណាយប្រតិបត្តិការអាទិភាព និងក្រសួង ឬស្ថាប័ន ព្រមទាំងមានបញ្ជាក់ពីការផ្តល់របាយការណ៍ទៅឲ្យភាគីពាក់ព័ន្ធសំខាន់ៗ ដូចជាដៃគូអភិវឌ្ឍ និងក្រុមការងារបច្ចេកទេសជាដើម។

(តទៅទំព័រ ១៧)

## ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយ.....

២. ការធ្វើសវនកម្មជាប្រចាំលើគម្រោងចំណាយប្រតិបត្តិការអាទិភាព

សវនកម្មដោយភាគីទីបី ជាលក្ខណៈឯករាជ្យលើចំណាយប្រតិបត្តិការអាទិភាពនីមួយៗនឹងត្រូវធ្វើឡើងជាប្រចាំ ដើម្បីធានាប្រសិទ្ធភាពនៃគម្រោង និងភាពស៊ីសង្វាក់គ្នាជាមួយនឹងតម្រូវការនៃការគ្រប់គ្រងហិរញ្ញវត្ថុ។ តម្រូវការនៃ សវនកម្មមានកំណត់នៅក្នុងកិច្ចសន្យាគ្រប់គ្រង ឬអាចដាក់ចេញដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រសួង ស្ថាប័ន ឬដៃគូអភិវឌ្ឍ។

៣. ការវាយតម្លៃលើឧបករណ៍ចំណាយប្រតិបត្តិការអាទិភាព

ការវាយតម្លៃលើឧបករណ៍ចំណាយប្រតិបត្តិការអាទិភាព (គម្រោងចំណាយប្រតិបត្តិការអាទិភាពទាំងអស់) នឹងត្រូវបានធ្វើឡើងដើម្បីជាការដកពិសោធន៍លើការអនុវត្តឧបករណ៍នេះ។ ការវាយតម្លៃនឹងត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងមានការពិភាក្សានៅក្នុងក្រុមការងារបច្ចេកទេសកំណែទម្រង់រដ្ឋបាលសាធារណៈ។ លទ្ធផលដែលបានពីការវាយតម្លៃនេះ នឹងត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់យោបល់លើឧបករណ៍ចំណាយប្រតិបត្តិការអាទិភាព។

(តទៅលេខក្រោយ)

## សម្រង់ប្រសាសន៍

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា...

អ្វីដែលជាសំណូមពរធំបំផុតរបស់ខ្ញុំនៅពេលនេះ គឺសូមឲ្យឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាមន្ត្រីរាជការធ្វើកិច្ចការដែលគប្បីចាំបាច់ត្រូវធ្វើដោយខានមិនបាន ក្នុងកាតព្វកិច្ចជាអ្នកបម្រើប្រជាពលរដ្ឋ មិនមែនជាអ្នកត្រួតត្រាប្រជាពលរដ្ឋ តែគឺជាខ្ញុំបំរើដ៏ល្អរបស់ប្រជាពលរដ្ឋ ហើយកែទម្លាប់ពីអ្នកគ្រប់គ្រង ពីចៅហ្វាយនាយឲ្យទៅជាអ្នកផ្តល់សេវា និងជាអ្នកបម្រើរបស់ប្រជាពលរដ្ឋឲ្យបានល្អ។

វាមិនលំបាកពេកទេដែលអ្នកជំតាំងខ្លួនទៅបម្រើប្រជាពលរដ្ឋ អត់មានអ្វីត្រូវសោកស្តាយទេ មួរដៃអាវលាត់ជើងខោចុះប្រឡូកការងារជាមួយប្រជាពលរដ្ឋ។

រាជរដ្ឋាភិបាលនីតិកាលទី៤នៃរដ្ឋសភាចង់បានបំផុតនោះគឺប្រសិទ្ធភាពនៃសេវាសាធារណៈ យើងចង់ឃើញរដ្ឋបាលសាធារណៈរបស់យើងជារដ្ឋបាលមួយដែលមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ងាយទទួលបានសេវា មន្ត្រីរាជការទទួលបានការលើកទឹកចិត្ត មានភាពស្មោះត្រង់ ថ្លៃថ្នូរ និងមានមនសិការក្នុងកិច្ចការផ្តល់សេវាបម្រើប្រជាពលរដ្ឋ។

កំណែទម្រង់រដ្ឋបាលសាធារណៈ មិនត្រឹមតែបានរួមចំណែកធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការផ្តល់សេវាសាធារណៈ និងកាត់បន្ថយភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាយន្តការពង្រឹងសមត្ថភាពស្ថាប័ន ដែលនឹងធ្វើឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបថរបស់មន្ត្រីរាជការទៀតផង។

សម្តេចតេជោ **ហ៊ុន សែន** គូសបញ្ជាក់ទៀតថា អ្វីដែលខ្ញុំចង់បានពិសេសបំផុតពីពេលនេះដល់ឆ្នាំ២០១៣ គឺប្រសិទ្ធភាពនៃសេវាសាធារណៈ។ បើអស់លោកជាមន្ត្រីធ្វើបានលើរឿងនេះ គឺវាពិសេសវិសាលណាស់សម្រាប់ជាតិ

(តទៅទំព័រ ២៣)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៨៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត និងដាក់ឲ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាព ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលដៅបង្កើត និងដាក់ឲ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាពក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ ស្របតាមគោលការណ៍សុខដុមនីយកម្ម ការតម្រឹម និងការកែតម្រូវ។

## ជំពូកទី ២

## គោលការណ៍នៃចំណាយប្រតិបត្តិការអាទិភាព

**មាត្រា២.-**

ចំណាយប្រតិបត្តិការអាទិភាព គឺជាចំណាយប្រតិបត្តិការសរុបសម្រាប់ផ្តល់ជូនមន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសឲ្យបំពេញការងារ ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ។ ចំណាយប្រតិបត្តិការអាទិភាពនឹងត្រូវបញ្ចប់នៅពេលលទ្ធផលដែលបានគ្រោងទុកត្រូវបានសម្រេច ឬ គម្រោង ឬ កម្មវិធីសហប្រតិបត្តិការអភិវឌ្ឍត្រូវបានបញ្ចប់។

**មាត្រា៣.-**

ចំណាយប្រតិបត្តិការអាទិភាពមិនមែនជាប្រាក់បៀវត្ស ឬ ជាប្រាក់ឧបត្ថម្ភបន្ថែមលើបៀវត្សឡើយ ។

**មាត្រា៤.-**

ក្នុងការអនុវត្តគម្រោងសហប្រតិបត្តិការអភិវឌ្ឍ ដៃគូអភិវឌ្ឍមិនអាចផ្តល់ជូនមន្ត្រីរាជការនូវចំណាយប្រតិបត្តិការណាមួយ ក្រៅពីចំណាយប្រតិបត្តិការអាទិភាពនេះឡើយ លើកលែងតែមានការអនុញ្ញាតជាផ្លូវការពីរាជរដ្ឋាភិបាល។

## ជំពូកទី ៣

## កម្រិតចំណាយប្រតិបត្តិការអាទិភាព

**មាត្រា៥.-**

ចំណាយប្រតិបត្តិការអាទិភាពសរុបក្នុងមួយខែ ត្រូវអនុវត្តតាមកម្រិតដូចខាងក្រោម ៖

១. កម្រិតចំណាយប្រតិបត្តិការអាទិភាពសម្រាប់ថ្នាក់ជាតិឬសេវាទ្រទ្រង់ មាន ៖

- ចំណាយប្រតិបត្តិការការងារដឹកនាំកម្មវិធី
  ពី ១ ៤៧០ ០០០ រៀល ទៅ ១ ៦៨០ ០០០ រៀល

- ចំណាយប្រតិបត្តិការការងារគ្រប់គ្រងគម្រោង
  ពី ៨៤០ ០០០ រៀល ទៅ ១ ២៦០ ០០០ រៀល
- ចំណាយប្រតិបត្តិការការងារប្រតិបត្តិ
  ពី ៥០៤ ០០០ រៀល ទៅ ៧៥៦ ០០០ រៀល

២. កម្រិតចំណាយប្រតិបត្តិការអាទិភាពសម្រាប់ថ្នាក់ក្រោមជាតិឬសេវាជួរមុខ មាន ៖

- ចំណាយប្រតិបត្តិការការងារគ្រប់គ្រងគម្រោង
  ពី ៣៧៨ ០០០ រៀល ទៅ ៤៦២ ០០០ រៀល
- ចំណាយប្រតិបត្តិការការងារប្រតិបត្តិ
  ពី ២១០ ០០០ រៀល ទៅ ២៩៤ ០០០ រៀល

៣. កម្រិតចំណាយប្រតិបត្តិការអាទិភាពសម្រាប់អ្នកឯកទេសកម្រិតខ្ពស់ នឹងត្រូវកំណត់ដោយឡែក បន្ទាប់ពីមានការឯកភាពរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ។

## ជំពូកទី ៤
## នីតិវិធីនៃការដាក់ឲ្យដំណើរការចំណាយប្រតិបត្តិការអាទិភាព

**មាត្រា៦.-**

ការកំណត់មុខសញ្ញាមន្ត្រីរាជការសម្រាប់បំពេញការងារក្នុងក្របខ័ណ្ឌចំណាយប្រតិបត្តិការអាទិភាព ត្រូវធ្វើឡើងដោយមានតម្លាភាព ផ្អែកលើលក្ខខណ្ឌយោង លក្ខណសម្បត្តិសក្តិសម មានសមធម៌ និងមាននីតិវិធី និងបែបបទច្បាស់លាស់ ។

**មាត្រា៧.-**

នីតិវិធីនិងបែបបទនៃការដាក់ឲ្យដំណើរការចំណាយប្រតិបត្តិការអាទិភាព ត្រូវកំណត់ក្នុងឯកសារណែនាំស្តីពីការអនុវត្តចំណាយប្រតិបត្តិការអាទិភាព ដែលរៀបចំដោយគណៈកម្មាធិការដឹកនាំការងារដើម្បីពិនិត្យ និងដោះស្រាយបញ្ហាប្រាក់ឧបត្ថម្ភបន្ថែមក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយមានការពិភាក្សាជាមួយដៃគូអភិវឌ្ឍ។

**មាត្រា៨.-**

ចំណាយប្រតិបត្តិការអាទិភាព ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# កំណាព្យ
## បណ្តាំក្រមង៉ុយ
( បទកាកគតិ )

កូនអើយធរណី បើតាមគម្ពីរ ដែលលោកសម្តែង
កុំចង់បានធំ ប្រមុំឆ្វៀលឆ្វែង កុំលើកដីឯង
លបដាក់ដីគេ។

អំពើអាក្រក់ មួយចំរៀកសក់ ធ្លាក់ទៅនិរយេ
បច្ចុប្បន្នលោកិយ កើតក្តីវាយជេរ មិនដែលសុខទេ
ព្រោះដីមួយហត្ថ។

កុំជួញចង់ទាស់ ខូចខាតរបស់ អស់ទ្រព្យសម្បត្តិ
ចង់គង់ប្រយោជន៍ ឲ្យចេះប្រយ័ត្ន ពាក្យឪមួយម៉ាត់
ឲ្យគិតមួយម៉ោង។

សំអាតផ្ចិតផ្ចង់ លើកភ្លឺឲ្យត្រង់ កុំលើកឲ្យកោង
អ្នកកុំប្រហែស ក្រែងមានប្រហោង លើកមើលទំនង
ទំនាបទឹកហូរ។

ចំនួនទឹកស្ទឹង ទឹកព្រែកទឹកបឹង ទឹកវាលទឹកអូរ
អ្នកលើលិចស្រូវ ត្រូវបើកបង្ហូរ អ្នកក្រោមកុំថ្ងូរ
បន្ទូរហួសទៅ។

រាំងរីងថ្ងៃយប់ ធាប់លើកធាប់ទប់ កុំឲ្យបាក់ជ្រៅ
កក្តិកចេញខ្យល់ តម្កល់ទឹកនៅ បើចង់បានស្រូវ
ស្រេចនៅត្រឹមថែ។



## សម្រង់ប្រសាសន៍
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា...

យើង ហើយភ័ព្វសំណាងណាស់សម្រាប់ប្រជាពលរដ្ឋយើង។ មន្ត្រីរបស់យើងភាគច្រើនហើយបានធ្វើកិច្ចការនេះ។

នៅពេលនេះ សេវារបស់យើងត្រូវធ្វើឲ្យបានល្អបំផុត ទឹកចិត្តអាណិតស្រឡាញ់ប្រជាពលរដ្ឋគ្មានព្រំដែនទេ យើងត្រូវធ្វើកិច្ចការងារបម្រើប្រជាពលរដ្ឋ។ ការអង្វរកររបស់ខ្ញុំនេះ វាជាកាតព្វកិច្ចដែលត្រូវធ្វើខានមិនបាន សេវាសាធារណៈត្រូវផ្តល់ឲ្យបានល្អបំផុត។

ត្រូវផ្លាស់ប្តូរទម្លាប់ ឥរិយាបថ របស់មន្ត្រីរាជការទាំងអស់ពីការពើងឫទ្ធិងដាក់ប្រជាពលរដ្ឋ ទៅជាបំរើប្រជាពលរដ្ឋឲ្យមានប្រសិទ្ធភាព។ បើនៅឲ្យគេស្រឡាញ់ កុំឲ្យដល់ពេលដើរចេញគេជេរ គេបាចអំបិល។ គឺត្រូវធ្វើយ៉ាងណាពេលដែលយើងនៅគេស្រឡាញ់ ដល់ពេលយើងផ្លាស់ប្តូរចេញឲ្យគេមានចិត្តអាណិតស្រឡាញ់តាមរក។

បើមិនបានជួយអ្វីដល់ប្រជាពលរដ្ឋ សូមកុំធ្វើបាបប្រជាពលរដ្ឋ ទាំងនៅច្រកអន្តរជាតិ ទាំងច្រកមិនអន្តរជាតិ ដែលប្រជាពលរដ្ឋទាំងសងខាងរកស៊ីជាមួយគ្នា បទប្បញ្ញត្តិណាដែលអត់ឲ្យយកលុយកុំយក គឺត្រូវជួយគាត់ថែមទៀត។ បើធ្វើកិច្ចការនេះបាន ហើយបញ្ហាអំពើពុករលួយវាអាចបាត់បង់ទៅឯង ព្រោះអត់មានការិយាធិបតេយ្យ ប្រជាពលរដ្ឋមករកអ្វីធ្វើជូនភ្លាមៗ។ ”

*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** មានប្រសាសន៍បែបនេះក្នុងឱកាសបិទអង្គសិក្ខាសាលាស្តីពីការផ្សព្វផ្សាយទិសដៅយុទ្ធសាស្ត្រ នៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល និងការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ ២០០៩-២០១៣ ។*

## មាតិកា


- សម្រង់ប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសបិទអង្គសិក្ខាសាលាស្តីពីការផ្សព្វផ្សាយទិសដៅយុទ្ធសាស្ត្រ ..............ទំព័រ១
- វគ្គបណ្តុះបណ្តាលស្តីពី ការកែលម្អការផ្តល់សេវាសាធារណៈ ដែលអនុវត្តនៅក្នុងរដ្ឋបាលសាធារណៈ ......................ទំព័រ១
- សិក្ខាសាលាក្រោមគម្រោង ស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅកម្ពុជា លើមុខវិជ្ជា "ការគ្រប់គ្រងវដ្តនៃគម្រោង" និង"វិធីសាស្ត្ររៀបចំករណីសិក្សា" .......... ទំព័រ១
- ឯកសារណែនាំ សម្រាប់ការអនុវត្តចំណាយប្រតិបត្តិការអាទិភាព ................................................................ទំព័រ៤
- ការចុះសិក្សាស្វែងយល់លើការផ្តល់ សេវាសាធារណៈវិស័យសុខាភិបាលនៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក មន្ទីរពេទ្យកុមារជាតិ និងមន្ទីរពេទ្យព្រះកុសុមៈ ...........ទំព័រ៨
- កំណាព្យ បណ្តាំក្រមង៉ុយ ............ .................................ទំព័រ២២


## ព្រឹត្តិបត្រព័ត៌មាន


| | |
|---|---|
| នាយកគ្រប់គ្រងទូទៅ | : ឯកឧត្តម **ថៅ ហុងលី** |
| និពន្ធនាយក | : ឯកឧត្តម **ឈួន ឆាម** |
| និពន្ធនាយករង | : ឯកឧត្តម **ប៉ូល ពីខូ** |
| នាយកគ្រប់គ្រងការផ្សាយ | : លោកជំទាវ **នាង លីណា** |
| នាយករងគ្រប់គ្រងការផ្សាយ | : លោក **មុយ ខួន** |
| នាយកទំនាក់ទំនង និងផ្សាយ | : លោក **អ៊ុក សុភាព** |
| អ្នកនិពន្ធ | : មន្ត្រីអគ្គលេខាធិការដ្ឋាននៃ**ក.ក.រ** |
| រូបភាព និង កុំព្យូទ័រ | : កញ្ញា **អ៊ុច នាងដាលីន** |



អគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី

Tel: (855-23) 221 470, 212 436

Fax: (855-23) 221 449

E-mail: npar@car.gov.kh

website: www.car.gov.kh

# កំណែទម្រង់រដ្ឋបាលសាធារណៈ

## Public Administration Reform

### បម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើង
### Serving People Better




មន្ត្រីរាជការស៊ីវិលបំពេញការងារប្រកបដោយ ឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវៈ និង វប្បធម៌សេវាសាធារណៈ នឹងធ្វើឱ្យរដ្ឋបាលសាធារណៈកាន់តែមាន តម្លាភាព ភាពឆ្លើយតប និង ប្រសិទ្ធភាព ដើម្បីបម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើង។

To Serve People Better, the public administration will become more transparent, responsive and efficient with civil servants upholding the values of motivation, loyalty, professionalism and a culture of service.